មើលវីដេអូ ភាគទី ២៨

# សេចក្តីសង្ស័យក្នុងព្រះអភិធម្ម ៨ យ៉ាងគឺ ៖

១- ពុទ្ធេ កង្ខតិ — សង្ស័យក្នុងព្រះពុទ្ធ គឺ ពុទ្ធគុណទាំង១០ មានពាក្យថា អរហំ ជាដើម ថាមានពិតឬហ្ន៎!

២- ធម្មេ កង្ខតិ — សង្ស័យក្នុងព្រះធម៌ គឺ ក្នុងធម្មគុណទាំង ៦ មានពាក្យថា ស្វាក្ខាតោ ជាដើម ថាមានពិតឬហ្ន៎!

៣- សង្ឃេ កង្ខតិ — សង្ស័យក្នុងព្រះសង្ឃ គឺក្នុងសង្ឃគុណទាំង ៩ មានពាក្យថា សុប្បដិបន្នោ ជាដើម ថាមានពិតឬហ្ន៎!

៤- សិក្ខាយ កង្ខតិ — សង្ស័យក្នុងសិក្ខាបទ គឺសិក្ខាបទទាក់ទង សីល សមាធិ និង បញ្ញា។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

| | |
|---|---|
| ៥- បុព្វន្តេ កង្ខតិ | សង្ស័យក្នុងខន្ធ៥ ដែលជាអតីត ថាធ្លាប់កើតមានដែរឬទេហ្ន៎! |
| ៦- អបរន្តេ កង្ខតិ | សង្ស័យក្នុងខន្ធ ៥ ជាអនាគត  ថានឹងកើតមានទៀតឬហ្ន៎! |
| ៧- បុព្វន្តាបរន្តេ កង្ខតិ | សង្ស័យក្នុងខន្ធ ៥ ដែលជាអតីតនិង អនាគតថាធ្លាប់កើតក្នុងអតីត ហើយនឹងកើតក្នុងអនាគតទៀតឬហ្ន៎! |
| ៨- បដិច្ចសមុប្បាទេ កង្ខតិ | សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ថា អវិជ្ជាជាដើម ជាបច្ច័យឱ្យកើតបាប និង បុណ្យ ឬឱ្យកើតផលបាប ឬបុណ្យ តើពិតមែន ឬហ្ន៎! |

# សេចក្ដីសង្ស័យក្នុងព្រះសូត្រមាន ១៦ យ៉ាង

## សង្ស័យក្នុងខន្ធ៥ ដែលជាចំណែកអតីត ៥ គឺ ៖

១- អហោសឹ នុ ខោ អហំ អតីតមទ្ធានំ យើងធ្លាប់កើតមកក្នុងអតីតកាលដែរឬហ្ន៎!

២- ន នុ ខោ អហោសឹ អតីតមទ្ធានំ យើងមិនធ្លាប់កើតមកក្នុងអតីតកាលទេដឹងហ្ន៎!

៣- កឹ នុ ខោ អហោសឹ អតីតមទ្ធានំ យើងធ្លាប់កើតក្នុងអតីតជាអ្វីហ្ន៎!

៤- កថំ នុ ខោ អហោសឹ អតីតមទ្ធានំ ក្នុងអតីតយើងមានរូបរាងសណ្ឋានដូចម្ដេចហ្ន៎!

៥- កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ អំពីអតីតកាល អាត្មាអញកើតជាជាតិអ្វី? ឬ មួយអាត្មាអញ មានសណ្ឋានទ្រង់ទ្រាយដូចម្ដេច!

# សេចក្ដីសង្ស័យក្នុងខន្ធ ៥ ដែលជាចំណែកអនាគត៥ គឺ ៖

១ - ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ យើងនឹងកើតក្នុងកាលអនាគតឬទេហ្ន៎!

២ - ន នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ យើងនឹងមិនកើតក្នុងកាលអនាគតទេដឹងហ្ន៎!

៣ - កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ យើងនឹងកើតក្នុងកាលអនាគតជាអ្វីហ្ន៎!

៤ - កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ ក្នុងអនាគតយើង នឹងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎!

៥ - កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ យើងនឹងកើតជាអ្វី! ហើយតទៅនឹងកើតជាអ្វីទៀតហ្ន៎!

# សង្ស័យក្នុងខន្ធ ៥ ដែលជាចំណែកបច្ចុប្បន្ន ៦ គឺ ៖

១- អហំ នុ ខោស្មិ ឥឡូវនេះជាយើងឬហ្ន៎!

២- នោ នុ ខោស្មិ ឥឡូវនេះមិនមែនជាយើងឬហ្ន៎!

៣- កឹ នុ ខោស្មិ ឥឡូវនេះយើងជាអ្វីហ្ន៎!

៤- កថំ នុ ខោស្មិ ឥឡូវនេះយើងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎!

៥- អយំ នុ ខោ សត្តោ កុតោ អាគតោ សត្វនេះមកពីណាហ្ន៎!

៦- សោ កុហឹ គាមី ភវិស្សតិ សត្វនោះនឹងទៅកើតទីណាហ្ន៎!

# ចែកមោហមូលចិត្តដោយន័យផ្សេង ៗ

| | |
|---|---|
| ១ - ដោយជាតិ | ជាអកុសលជាតិ |
| ២ - ដោយភូមិ | ជាកាមាវចរភូមិ (កើតក្នុងភូមិទាំងអស់ វៀរអសញ្ញសត្តា)។ |
| ៣ - ដោយវេទនា | ជាឧបេក្ខាវេទនាទាំង ២ ដួង |
| ៤ - ដោយហេតុ | ជានហេតុ និង ជាឯកហេតុកចិត្ត |
| ៥ - ដោយសង្ខារ | ជាសង្ខារវិមុត្ត (ជាអសង្ខារិកៈក៏មិនមែន ជាសសង្ខារិកៈក៏មិនមែន) |
| ៦ - ដោយសម្បយុត្ត | ជាវិចិកិច្ឆាសម្បយុត្ត ១ និង ឧទ្ធច្ចសម្បយុត្ត ១ |

| | |
|---|---|
| ៧- ដោយសោភណ | ជាអសោភណចិត្ត |
| ៨- ដោយឈាន | ជាអឈានចិត្ត |
| ៩- ដោយលោកិយ | ជាលោកិយចិត្ត |
| ១០- ដោយកិច្ច | ធ្វើជវនកិច្ច |
| ១១- ដោយអារម្មណ៍ | ដឹងអារម្មណ៍ ៦ |
| ១២- ដោយទ្វារ | កើតតាមទ្វារទាំង ៦ |
| ១៣- ដោយវត្ថុ | កើតក្នុងហទយវត្ថុ ក្នុងភពដែលមានខន្ធ ៥ (ក្នុងភូមិ ២៦)។ |
| ១៤- ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ |

# ផលរបស់មោហមូលចិត្ត

- ក្នុងបច្ចុប្បន្ន កាលណាសត្វលោកច្រើនទៅដោយមោហៈគឺសេចក្តីល្ងង់ សេចក្តីវង្វេង ក្នុងកាលនោះ ច្រើនមានសេចក្តីអន្តរាយដោយរោគបៀតបៀន។

- ក្នុងអនាគតជាតិ ព្រោះតែមោហៈជាហេតុ សត្វលោកច្រើនបដិសន្ធិក្នុងកំណើតតិរច្ឆាន ដែលមានតែសេចក្តីវង្វេងជានិច្ច។

# សម្បយោគន័យ

## ក្នុងអកុសលចិត្ត ១២ ដួង

ក្នុងអកុសលចិត្ត ១២ ដួង មានចេតសិកកើតរួមសរុប ២៧

គឺ អញ្ញសមានាចេតសិក ១៣ និង អកុសលចេតសិក ១៤។

## ១ - ចេតសិកដែលកើតនៅក្នុងអកុសលចិត្តគ្រប់ទាំង ១២ ដួង មានត្រឹមតែ ១៤ ប្រភេទប៉ុណ្ណោះ គឺ ៖

- សព្វចិត្តសាធារណចេតសិក ៧ គឺ ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយៈ មនសិការ

- បកិណ្ណកចេតសិក ៣ គឺ វិតក្កៈ វិចារៈ វិរិយៈ *(វៀរលែង អធិមោក្ខៈ បីតិ ឆន្ទៈ)*

- មោចតុក្កៈ ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ។

ចេតសិកទាំង ១៤ ខាងលើនេះ អាចហៅថា

សព្វាកុសលយោគីចេតសិក។

សព្វាកុសលយោគីចេតសិក មកពី

សព្វ + អកុសល + យោគី + ចេតសិក ចេតសិក

ដែលកើតនៅក្នុងអកុសលចិត្តគ្រប់ទាំង ១២ ដួង ។

២ - អធិមោក្ខ:	កើតនៅក្នុងអកុសលចិត្ត ១១ ប៉ុណ្ណោះ (វៀរ វិចិកិច្ឆាសម្បយុត្តចិត្ត១)។

៣ - បីតិ	កើតនៅក្នុងលោភមូលចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ៤ ដួងប៉ុណ្ណោះ។

៤- ឆន្ទៈ	កើតនៅក្នុងអកុសលចិត្ត ១០ ដួងប៉ុណ្ណោះ (វៀរមោហមូលចិត្ត ២ ដួង) ។

៥- លោភៈ	កើតនៅក្នុងលោភមូលចិត្ត ៨ ដួងប៉ុណ្ណោះ។

| | |
|---|---|
| ៦ - ទិដ្ឋិ | កើតនៅក្នុងលោភមូលចិត្ត ដែលជាទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួងប៉ុណ្ណោះ។ |
| ៧ - មានោ | កើតនៅក្នុងលោភមូលចិត្តដែលជាទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួងប៉ុណ្ណោះ។ |
| ៨ - ទោចតុក្កៈ ៤ | គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ កើតតែក្នុងទោសមូលចិត្ត ២ ដួង។ |
| ៩ - ថីទុកៈ ២ | គឺ ថីនៈ មិទ្ធៈ កើតនៅក្នុងសសង្ខារិកចិត្ត ៥ ដួង។ |
| ១០ - វិចិកិច្ឆា | កើតនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង។ |